



# វិធីបំបាត់ភាពក្រីក្រ

ដោយ សំ វិជ្ជា

ថ្ងៃទី១២ តុលា ២០០៩

អមដោយរូបភាព និងគំនូរ អ៊ុង ប៊ុនហ៊ាង

១. នេះជាវិធី គេថាល្អ?!! «បំបាត់ភាពក្រ» ដោយឈូសឆាយ
ឈូសចេញឲ្យអស់»ក្រ»ទាំងឡាយ! ខ្វល់ខ្វាយ បណ្តុះពូជ«អ្នកមាន» ។
២. គឺជាគម្រោង រដ្ឋសព្វថ្ងៃ ដីមានតម្លៃប្រាក់រាប់លាន
ឈូស«ភាពក្រីក្រ»ឆាយរុករាន តាមបែប«សម្បទាន, អភិវឌ្ឍន៍» ។
៣. ទាំងដីក្រហម សំបុកចាប មានក្លិនស្អុយឆ្អាប«អាប់ដល់រដ្ឋ»
បឹងកក់ល្អក់ស្អុយ ចាក់ដីញាត់ ឲ្យ«រដ្ឋ»ចាត់ចែងបែងកុងត្រា ។
៤. ពេលនោះអ្នកមាន គេចូលមក អ្នកក្រខ្វះជ្រក អត់អាហារ
ខ្លះក៏ជ្រកតាមសន្យាបផ្សារ គឺជាគ្រោងការណ៍សង្គមថ្មី ។
៥. កូរ៉េ ចិន យួន ខ្លួនគេមាន គេមករុករាន ទិញយកដី
វិធី«បំបាត់ភាពក្រក្រី»! ស្នាដៃដ៏ល្បីស្អាចម៍ដែកជោរ ៕